# 3 ការការពារធនធានធម្មជាតិ សម្រាប់មនុស្សគ្រប់គ្នា

**នៅក្នុងជំពូកនេះ :** **ទំព័រ**


មូលហេតុនៃបញ្ហាសុខភាពបរិស្ថាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 22
ការគ្រប់គ្រងពីសាជីវកម្ម គឺមិនល្អសម្រាប់សុខភាពយើងទេ . . . . . . . . . . . . . . . . . . . . . 24
ការបង្កើតស្ថាប័នក្នុងសហគមន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 25
ការធ្វើឲ្យសហគមន៍របស់យើងមានស្ថិរភាព. . . . . . . . . . . . . . . . . . . . . . . . . . . . . . . 26
ការគោរពសំណាញ់នៃជីវិត. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 27
ការធ្វើការជាមួយធម្មជាតិ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 30
តើយើងអាចធ្វើតាមវដ្តធម្មជាតិបានយ៉ាងដូចម្តេច . . . . . . . . . . . . . . . . . . . . . . . . . . . 31
តើឧស្សាហកម្មអាចធ្វើតាមវដ្តធម្មជាតិបានយ៉ាងដូចម្តេច . . . . . . . . . . . . . . . . . . . . . . . 31
ការបង្ការគ្រោះថ្នាក់ពីការបំពុលបរិស្ថាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 32
គោលការណ៍ប្រុងប្រយ័ត្ន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 32
ការឡើងកម្តៅផែនដី . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 33

# ការការពារធនធានធម្មជាតិ សម្រាប់មនុស្សគ្រប់គ្នា



ការប្រើប្រាស់ធនធានធម្មជាតិ ធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់យើង និងសុខភាពសហគមន៍យើងទាំងអស់គ្នា។ ដោយសារតែមនុស្សគ្រប់គ្នាប្រើប្រាស់ធនធានធម្មជាតិ ដូច្នេះយើងទាំងអស់គ្នាមានតួនាទីក្នុងការការពារ, អភិរក្ស, និងចែករំលែកធនធានទាំងនេះ។

ជាអកុសល ធនធានធម្មជាតិមិនត្រូវបានចែករំលែកស្មើគ្នានោះទេ។ អ្នកក្រប្រើប្រាស់ធនធានធម្មជាតិបានតិចតួច រីឯអ្នកមានប្រើប្រាស់បានយ៉ាងច្រើន។ ជាញឹកញាប់អ្នកដែលមានអំណាច ដូចជាសាជីវកម្ម រដ្ឋាភិបាល និងទាហាន បានដណ្តើមយកធនធានធម្មជាតិមួយចំណែកយ៉ាងធំ។ សូម្បីនៅក្នុងសហគមន៍តែមួយ ក៏អ្នកមានប្រើប្រាស់ធនធានធម្មជាតិច្រើនជាងអ្នកក្រដែរ។ ជាញឹកញាប់ ប្រជាជនក្រីក្របានបង្ខំចិត្តឈ្លោះដណ្តើមគ្នានូវធនធានដែលនៅសល់តិចតួចនោះ។ ការបែងចែកធនធានមិនស្មើភាពគ្នា នាំឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរដល់ប្រជាជនក្រីក្រ។

យើងអាចនិយាយអំពីការអភិរក្សធនធានធម្មជាតិជារៀងរាល់ថ្ងៃ ប៉ុន្តែដរាបណាវិសមភាពនៅតែបន្តកើតមាន នោះសុខភាពបរិស្ថាននឹងក្លាយជាសិទ្ធមួយសម្រាប់តែអ្នកមានទ្រព្យសម្បត្តិនិងមានអំណាចមួយចំនួនតូចប៉ុណ្ណោះ គឺមិនមែនសម្រាប់មនុស្សជាច្រើនដែលត្រូវការធនធានទាំងនេះដើម្បីការរស់រានប្រចាំថ្ងៃទេ។ ដូចដែលអ្នកដឹកនាំឥណ្ឌា មហាត្មៈគន្ធី បានមានប្រសាសន៍ថា "យើងអាចបំពេញតម្រូវការរបស់មនុស្សបាន ប៉ុន្តែយើងមិនបំពេញភាពលោភលន់របស់មនុស្សទេ"។

# មូលហេតុនៃបញ្ហាសុខភាពបរិស្ថាន



វិធីមួយក្នុងការពិចារណាអំពីមូលហេតុនៃបញ្ហាសុខភាពបរិស្ថានគឺ ៖

- **ភាពខ្វះខាត**នៃរបស់សំខាន់ៗដែលយើងត្រូវការដើម្បីជីវិតសុខភាព ដូចជាខ្យល់ និងទឹកស្អាត, ដីមានជីជាតិ, ព្រៃឈើច្រើន, ផ្ទះសម្បែងមានសុវត្ថិភាពនិងជាសុក, និងស្ថានភាពការងារមាន សុវត្ថិភាព។
- **ភាពលើសលុប**នៃរបស់មានគ្រោះថ្នាក់ដែលយើងមិនត្រូវការ ដូចជា សំរាម, សារធាតុគីមីពុល, ការបំពុលបរិស្ថាន, និងអាហារវេចខ្ចប់។

ក្នុងសាច់រឿងពីប្រទេសអេខ្វាឌ័រ(មើលជំពូក1) បញ្ហាសុខភាពបានកើតឡើងដោយសារភាពខ្វះខាតនៃរបស់ចាំបាច់សំខាន់ៗ ដូចជា ទឹកស្អាត បង្គន់ និងដើមឈើ។ ក្នុងសាច់រឿងពីទីក្រុងបូប៉ាល់(Bhopal) នៃប្រទេសឥណ្ឌា(មើលជំពូក4) បញ្ហាសុខភាពបានកើតឡើងដោយសារភាពលើសលុបនៃសារធាតុគីមីពុល។

ក្នុងរឿងនីមួយៗ ការកែលម្អសុខភាពបរិស្ថាន គឺអាស្រ័យលើប្រជាជន។ ពួកគេអាចបង្ការស្ថានភាពដែលបណ្តាលឲ្យមានភាពខ្វះខាតនៃធនធានសំខាន់ៗសម្រាប់ជីវិត និងភាពលើសលុបនៃការបំពុលបរិស្ថាន។ តាមរយៈការការពារសហគមន៍ និងធនធានធម្មជាតិ គឺយើងកំពុងការពារអនាគតរបស់កូនៗនិងចៅៗរបស់យើងទាំងអស់គ្នា។



# មនុស្សច្រើនពេក ធនធានតិចពេក?

បរិមាណទឹក ដើមឈើ រ៉ែ និងធនធានធម្មជាតិដទៃទៀតនៅលើផែនដី គឺមានកំណត់ ប៉ុន្តែចំនួនប្រជាជនដែលប្រើប្រាស់ធនធានទាំងនេះ កំពុងកើនឡើងយ៉ាងឆាប់រហ័ស។ គ្រប់ពេលដែលមនុស្សម្នាក់ឬមនុស្សមួយក្រុមប្រើប្រាស់ធនធានច្រើនលើសពីចំណែកសមរម្យរបស់ខ្លួន ឬធ្វើឲ្យមានការបំពុលបរិស្ថានច្រើនលើសលុប នោះអតុល្យភាពនេះអាចបណ្តាលឲ្យមានបញ្ហាសុខភាពដល់អ្នកដទៃ។

**ការពន្យល់របស់អ្នកមាន អំពីភាពក្រីក្រនិងការបំផ្លាញបរិស្ថាន ៖** មនុស្សមានច្រើនពេក ប៉ុន្តែដីធ្លីនិងធនធានមានតិចពេក។



**ការពន្យល់របស់ប្រជាជនក្រីក្រ អំពីភាពក្រីក្រនិងការបំផ្លាញបរិស្ថាន ៖** ការបែងចែកដីធ្លីនិងធនធាន គឺមិនស្មើភាពគ្នា ចំណែកភាគច្រើនបានធ្លាក់ទៅក្នុងដៃមនុស្សភាគតិច។




មនុស្សមួយចំនួនជឿថា វិធីដ៏ល្អបំផុតក្នុងការបង្ការគ្រោះថ្នាក់ដល់បរិស្ថាន គឺការកាត់បន្ថយចំនួនមនុស្ស។ គំនិតបែបនេះបានឈានទៅដល់កម្មវិធី "គ្រប់គ្រងចំនួនប្រជាជន"។ កម្មវិធីនេះបានទទួលបរាជ័យគ្រប់កន្លែងក្នុងការកែលម្អជីវភាពរបស់មនុស្ស ព្រោះវាមិនបានគូសបញ្ជាក់អំពីមូលហេតុឫសគល់នៃការបំផ្លាញបរិស្ថាន ភាពក្រីក្រ និងសុខភាពមិនល្អទេ។ នៅពេលគ្រួសារខ្លះមានធនធានចាំបាច់គ្រប់គ្រាន់ក្នុងការរស់នៅប្រកបដោយសុខភាពល្អនិងមានកិត្តិយស, មនុស្សជាច្រើនបានជ្រើសរើសយកការមានកូនតិច។ លុះត្រាតែសហគមន៍ រដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍នានា ធ្វើផែនការដើម្បីការរស់រានរបស់កុមារនិងដើម្បីការកែលម្អផ្នែកសង្គម នយោបាយ និងស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី, នោះទើប "បញ្ហាចំនួនប្រជាជន" នេះអាចត្រូវបានដោះស្រាយរួច។

ប៉ុន្តែការកាត់បន្ថយចំនួនប្រជាជននៅក្នុងពិភពលោក នឹងមិនគូសបញ្ជាក់អំពីបញ្ហានៃការប្រើប្រាស់ធនធានមិនស្មើគ្នានោះទេ។ វិធីល្អបំផុតក្នុងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន គឺត្រូវឲ្យអ្នកមានប្រើប្រាស់ធនធានតិច ហើយប្រើប្រាស់វាក្នុងវិធីមួយដែលអភិរក្សនូវធនធាននេះសម្រាប់ពេលអនាគត ព្រមទាំងមិនធ្វើឲ្យមានការបំពុលបរិស្ថានយ៉ាងលើសលុបទៀតផង។ តាមរយៈការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកប្រើប្រាស់ធនធានភាគច្រើនជាមុន នោះយើងអាចចាប់ផ្តើមធ្វើឲ្យប្រាកដថា នឹងមានធនធានគ្រប់គ្រាន់ដើម្បីឲ្យមនុស្សគ្រប់គ្នាមានជីវិតប្រកបដោយសុខភាពល្អ។

## ការគ្រប់គ្រងពីសាជីវកម្ម គឺមិនល្អសម្រាប់សុខភាពយើងទេ

វិបត្តិផ្នែកសុខភាពនៅលើឆ្នេរអេខ្វាឌ័រ(មើលជំពូក1) ត្រូវបានបង្កឡើងដោយសាជីវកម្មធំមួយដែលបានចំណាយប្រាក់ឲ្យប្រជាជនក្នុងតំបន់នោះកាប់ព្រៃឈើ។ ប្រជាជនមិនត្រឹមតែបាត់បង់ដើមឈើដែលធ្វើឲ្យដីមានជីជាតិនិងការពារពីព្យុះប៉ុណ្ណោះទេ ពួកគេថែមទាំងបាត់បង់នូវធនធានសំខាន់ៗសម្រាប់ការរស់រានប្រចាំថ្ងៃទៀតផង ដែលមានដូចជា អាហារ ឧស ឱសថ អំបោះ និងរបស់ចាំបាច់ដទៃទៀត។ នៅពេលដែលធនធានទ្រង់ទ្រាយធំ, ដូចជាព្រៃឈើ, មិនអាចបំពេញមកវិញបាន នោះវាដូចជាត្រូវបានលួចទៅបាត់ដូច្នេះដែរ គឺលួចពីធម្មជាតិ, លួចពីសហគមន៍ដែលអាស្រ័យលើធនធាននោះ, និងលួចពីមនុស្សជំនាន់ក្រោយៗទៀត។

នៅពេលសាជីវកម្មគ្រប់គ្រងលើធនធាន(ទោះជាឈើ ប្រេង ទឹក គ្រាប់ពូជ ឬកម្លាំងពលកម្មរបស់ប្រជាជនក៏ដោយ) ពួកគេរកប្រាក់ចំណូលសម្រាប់ខ្លួនឯង ហើយពួកគេមិនសូវជាចង់ការពារឬកែលម្អជីវភាពរបស់ប្រជាជនដែលត្រូវការធនធានទាំងនោះដើម្បីរស់រានទេ។ សាជីវកម្មអាចផ្តល់ជាការងារឬប្រាក់ចំណូលក្នុងរយៈពេលខ្លី ប៉ុន្តែប្រសិនបើផលប្រយោជន៍របស់ពួកគេគឺដើម្បីនាំចេញនូវធនធានក្នុងស្រុក នោះពួកគេក៏នឹងចាកចេញទៅដែរនៅពេលដែលប្រើប្រាស់ធនធានទាំងនោះអស់។ បន្ទាប់មកប្រជាជននឹងស្ថិតក្នុងភាពក្រីក្រកាន់តែជ្រៅជាងមុន។



# ការបង្កើតស្ថាប័នក្នុងសហគមន៍

ការគ្រប់គ្រងធនធានធម្មជាតិដោយយុត្តិធម៌និងដោយស្មើភាពគ្នា មានន័យថាមនុស្សទាំងអស់អាចបញ្ចេញមតិយោបល់នៅក្នុងការសម្រេចអំពីការប្រើប្រាស់ និងចែករំលែកធនធានធម្មជាតិ។ ការគ្រប់គ្រងដោយយុត្តិធម៌និងដោយស្មើភាពគ្នា អាចមានជាច្រើនទម្រង់ ប៉ុន្តែទម្រង់ទាំងអស់សុទ្ធតែផ្អែកលើការអប់រំ និងការរៀបចំចាត់ចែងប្រជាជនឲ្យធ្វើការងាររួមគ្នាដើម្បីការផ្លាស់ប្តូរ។

សុខភាពបរិស្ថានតែងតែជាបញ្ហារបស់សហគមន៍។ ប្រជាជនត្រូវតែធ្វើការងាររួមគ្នាជាសហគមន៍មួយដើម្បីការពារនូវធនធានដែលពួកគេត្រូវការដូចគ្នា។ ដើម្បីធ្វើការងាររួមគ្នាយូរអង្វែង ជាទូទៅប្រជាជនបង្កើតជាក្រុមឬស្ថាប័នក្នុងសហគមន៍។

នៅពេលជំងឺអាសន្នរោគបានចាប់ផ្តើមរាតត្បាតនៅក្នុងប្រទេសអេក្វាឌ័រ គម្រោង"សុខភាពសម្រាប់ប្រជាជន" បានរៀបចំជាគណៈកម្មាធិការសុខភាពសាធារណៈ ដើម្បីទទួលបន្ទុកលើការលើកកម្ពស់ការយល់ដឹងអំពីជំងឺនិងជំរុញឲ្យប្រជាជនធ្វើសកម្មភាពផ្សេងៗ។ ដើម្បីឆ្លើយតបឲ្យកាន់តែប្រសើរទៅកាន់ការរាតត្បាតនៃជំងឺអាសន្នរោគ គណៈកម្មាធិការសុខភាពសាធារណៈបានផ្តល់នូវចំណេះដឹង(វិធីធ្វើភេសជ្ជៈបង្ករប់ជាតិទឹក) និងសេវាផ្សេងៗ(សាងសង់បង្គន់ថ្មីៗនិងប្រព័ន្ធទឹកស្អាត)។ ពួកគេក៏បានជួយស្រោចស្រង់និងពង្រឹងសហគមន៍របស់ពួកគេឡើងវិញ តាមរយៈការថែទាំគ្លីនិកសុខភាព និងការផ្តល់សេវាអប់រំនិងបណ្តុះបណ្តាលនៅតាមសាលារៀន សួនច្បារ និងនៅតាមផ្ទះប្រជាជន។ ពួកគេបានធ្វើជាគំរូឲ្យប្រជាជនដទៃទៀតដើម្បីបង្កើតជាក្រុមនិងស្ថាប័នផ្សេងៗ ដូចជាក្រុមអ្នកលើកកម្ពស់សុខភាពបរិស្ថាន និងកម្មវិធីកែច្នៃធនធានឡើងវិញ។




គម្រោង"សុខភាពសម្រាប់ប្រជាជន" ក៏បានធ្វើការងារជាមួយអង្គការដទៃទៀតដែលនៅក្រៅសហគមន៍របស់ពួកគេ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភ, ជំនាញវិស្វកម្ម, ថ្នាំពេទ្យ, និងធនធានដទៃទៀត។ ពួកគេបានធ្វើឲ្យប្រាកដថាធនធានទាំងនេះត្រូវបានប្រើប្រាស់និងគ្រប់គ្រងដោយអ្នកភូមិផ្ទាល់។ សហគមន៍ទាំងនេះក៏បានចូលរួមនៅក្នុងការរៀបចំផែនការ និងការសម្រេចចិត្តអំពីការពង្រីកកម្មវិធីរបស់ពួកគេផងដែរ។

នៅពេលដែលរដ្ឋាភិបាលមិនផ្តល់ឲ្យប្រជាជនរបស់ពួកគេនូវតម្រូវការសំខាន់ៗ, ប្រជាជនត្រូវតែបង្កើតស្ថាប័នផ្សេងៗដោយខ្លួនឯង ដូចដែលគម្រោង"សុខភាពសម្រាប់ប្រជាជន" បានធ្វើដូច្នេះដែរ ដើម្បីធានាថាពួកគេនឹងមានសុខភាពល្អនៅថ្ងៃអនាគត។ ជារឿយៗនៅពេលដែលសហគមន៍រៀបចំសកម្មភាពរបស់ខ្លួន រដ្ឋាភិបាលក៏ចាប់ផ្តើមឆ្លើយតបដែរ ដោយបំពេញតាមការទទួលខុសត្រូវរបស់ខ្លួនដែលមានចំពោះប្រជាជន។

តម្រូវការធនធានខុសៗគ្នារវាងបុរសនិងស្ត្រី, រវាងកម្មករ កសិករ មេព្រៃ និងម្ចាស់កសិដ្ឋាន, រវាងឧស្សាហកម្ម អ្នកអភិវឌ្ឍន៍ដីធ្លី និងអ្នកដទៃទៀត, អាចនាំឲ្យមានជម្លោះនៅក្នុងសហគមន៍របស់អ្នក។ ជួនកាលបញ្ហាខ្លះអាចពិបាកនឹងដោះស្រាយខ្លាំងណាស់ ដូចជាការថ្លឹងថ្លែងរវាងតម្រូវការប្រាក់ចំណូលក្នុងរយៈពេលខ្លីនិងតម្រូវការសុខភាពក្នុងរយៈពេលវែង។ ការបង្កើតស្ថាប័ននៅក្នុងសហគមន៍ឲ្យមានលក្ខណៈរឹងមាំ តែងតែត្រូវការពេលវេលាយ៉ាងយូរ ព្រោះការទទួលស្គាល់ភាពខុសគ្នា និងការព្យាយាមដោះស្រាយជម្លោះ គឺជាការងារដ៏លំបាក។ ការកំណត់គោលដៅដើម្បីសុខភាពយូរអង្វែង និងការស្វែងរកវិធីផ្សេងៗដើម្បីឲ្យមនុស្សគ្រប់គ្នាធ្វើការងារឆ្ពោះទៅរកគោលដៅនេះរួមគ្នា, អាចជួយដោះស្រាយជម្លោះដែលពិបាកៗ និងជួយបង្កើតស្ថាប័នដ៏រឹងមាំដែលការពារផលប្រយោជន៍រួមទៀតផង។

# ការធ្វើឲ្យសហគមន៍របស់យើងមានស្ថិរភាព

ស្ថិរភាពមានន័យថា លទ្ធភាពក្នុងការថែរក្សាអ្វីមួយឲ្យនៅគង់វង្សយូរអង្វែង។ ទោះជាយើងកំពុងនិយាយអំពីស្ថាប័នក្នុងសហគមន៍ ដូចជាគ្លីនិកសុខភាព ឬកម្មវិធីកែច្នៃធនធានឡើងវិញ ឬអំពីធនធានធម្មជាតិ ដូចជាព្រៃឈើ ស្រែចម្ការ ឬកន្លែងទឹកចេញក៏ដោយ, ប្រសិនបើវាមិនត្រូវបានអភិវឌ្ឍនិងប្រើប្រាស់ឲ្យមានស្ថិរភាពទេ នោះបញ្ហាសុខភាពបរិស្ថានធ្ងន់ធ្ងរនឹងអាចកើតឡើង។

ស្ថិរភាពក៏អាចមានន័យថា ជាការអាចបំពេញតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន ខណៈដែលកំពុងរៀបចំផែនការសម្រាប់តម្រូវការរបស់មនុស្សជំនាន់ក្រោយផងដែរ។ ឧបសគ្គចម្បងបំផុតមួយដែលប្រជាជនកំពុងប្រឈមសព្វថ្ងៃ គឺការព្យាយាមបំពេញនូវរាល់តម្រូវការរបស់យើងដោយមិនឲ្យបង្កគ្រោះថ្នាក់ដល់បរិស្ថានដែលជាអ្នកផ្តល់អាហារ ជម្រក និងសម្លៀកបំពាក់, ដែលផ្តល់ជាទឹក ថាមពល និងឱសថ, និងដែលជាប្រភពដ៏សំខាន់សម្រាប់ការរស់រានរបស់យើង។

នៅជុំវិញខ្លួនយើង យើងឃើញសញ្ញានៃការអភិវឌ្ឍន៍ដែលគ្មានស្ថិរភាព។ ភាពខ្វះខាតនៃអាហារសុខភាព ខ្យល់និងទឹកស្អាត និងការចិញ្ចឹមជីវិតប្រកបដោយសុវត្ថិភាព, មានកាន់តែច្រើនឡើងៗ។ ការបំពុលបរិស្ថាន ការកាប់បំផ្លាញព្រៃឈើ និងជំងឺផ្សេងៗ, ក៏មានច្រើនយ៉ាងខ្លាំងដែរ។ នៅពេលដែលសហគមន៍លូតលាស់ក្នុងរបៀបម្យ៉ាងដែលគ្មានស្ថិរភាព នោះពួកគេបង្កើតបញ្ហាយ៉ាងធំសម្រាប់ខ្លួនឯង និងសម្រាប់មនុស្សជំនាន់ក្រោយថែមទៀត។

នៅក្នុងសៀវភៅនេះ ជាពិសេសនៅក្នុងសាច់រឿងដែលយើងបានប្រមូលចងក្រង, យើងបានផ្តល់ឧទាហរណ៍អំពីគោលការណ៍មូលដ្ឋានមួយចំនួនស្តីអំពីស្ថិរភាព។ គោលការណ៍សំខាន់បំផុតមួយចំនួន ត្រូវបានរៀបរាប់នៅទំព័របន្តបន្ទាប់នេះ។



# ការគោរពសំណាញ់នៃជីវិត

ពិភពធម្មជាតិផ្សំឡើងពីវត្ថុមានជីវិតជាច្រើនប្រភេទផ្សេងៗគ្នា។ ពាក្យវិទ្យាសាស្ត្រដែលសំដៅលើប្រភេទផ្សេងៗគ្នាយ៉ាងច្រើននៃមនុស្ស រុក្ខជាតិ សត្វ និងសត្វល្អិតដែលរស់នៅលើផែនដីនេះ ហៅថា ជីវចម្រុះ។ កាលដើមឡើយ នៅមុនពេលដែលអ្នកវិទ្យាសាស្ត្រផ្តល់ពាក្យនេះទៅលើភាពសម្បូរបែបនៃវត្ថុមានជីវិត, មនុស្សជាច្រើនបានបង្រៀនកូនចៅរបស់ខ្លួនអំពីសំណាញ់នៃជីវិត។ ដូចគ្នានឹងសំណាញ់ពីងពាងដែលមានភាពរឹងមាំដោយសារសរសៃជាច្រើនតភ្ជាប់គ្នាដែរ, ជីវចម្រុះពឹងផ្អែកទៅលើសំណាញ់នៃជីវិតដែលតភ្ជាប់រវាងវត្ថុមានជីវិតទាំងឡាយនៅក្នុងលោកយើងនេះ។

ឧទាហរណ៍ ប្រជាជនបេះផ្លែឈើយកមកបរិភោគដែលមានសារជាតិចិញ្ចឹម ធ្វើឲ្យពួកគេមានសុខភាពល្អ។ ផ្លែឈើទាំងនេះដុះនៅលើដើមឈើឬគម្ពោតដែលសត្វល្អិតបានរោយលម្អងពីលើ។ បើគ្មានការរោយលម្អងទេ ផ្លែឈើមិនអាចលូតលាស់ធំបានទេ។ សត្វស្លាបស៊ីសត្វល្អិត, ហើយសត្វកញ្ជ្រោងស៊ីសត្វស្លាប។ តុល្យភាពក្នុងសំណាញ់នៃជីវិត មានន័យថា ផ្កា សត្វល្អិត សត្វស្លាប និងសត្វកញ្ជ្រោង គឺមានល្មមតែគ្រប់គ្រាន់ដែលអាចឲ្យវាទាំងអស់នេះរស់នៅក្នុងកន្លែងជាមួយគ្នា។ បើអ្នកសម្លាប់សត្វកញ្ជ្រោងច្រើនពេក (អាចដោយសារតែវាស៊ីមាន់របស់អ្នក) នោះចំនួនសត្វស្លាបអាចនឹងកើនឡើង ហើយពួកវានឹងស៊ីសត្វល្អិតយ៉ាងច្រើន។ ក្នុងឧទាហរណ៍នេះ ការសម្លាប់សត្វកញ្ជ្រោងច្រើនពេក អាចមានន័យថា អ្នកនឹងមានផ្លែឈើតិចដែរ។



**ផ្នែកដ៏សំខាន់មួយក្នុងការការពារសុខភាពរបស់មនុស្សក្នុងពេលបច្ចុប្បន្ន និងអនាគត គឺការការពារសំណាញ់នៃជីវិត។**

ជាអកុសល ពិភពលោកនេះកំពុងតែប្រឈមនឹងការបាត់បង់ជីវចម្រុះយ៉ាងច្រើន ក្នុងនោះមានរុក្ខជាតិនិងសត្វជាច្រើនប្រភេទបានផុតពូជជារៀងរាល់ឆ្នាំ។ ជីវចម្រុះមានសារសំខាន់ណាស់ ហើយវាមានប្រយោជន៍ច្រើនយ៉ាងក្នុងការការពារសុខភាពមនុស្ស។

## ការបំផ្លាញសំណាញ់នៃជីវិត នាំឲ្យកើតមានជំងឺថ្មី។

ការបាត់បង់ជីវចម្រុះ មានន័យថារុក្ខជាតិនិងសត្វប្រភេទខ្លះត្រូវបានបាត់បង់ ហើយតុល្យភាពធម្មជាតិក្នុងចំណោមរុក្ខជាតិ សត្វ និងមនុស្ស ក៏ត្រូវបានរំខាន។ បែបនេះអាចធ្វើឲ្យកើតមានជំងឺថ្មីៗ។ ខាងក្រោមនេះគឺជាឧទាហរណ៍២យ៉ាងដែលបង្ហាញថា ការបាត់បង់ជីវចម្រុះដោយសារការកាប់បំផ្លាញព្រៃឈើ អាចធ្វើឲ្យកើតមានជំងឺបានយ៉ាងដូចម្ដេច ៖

- នៅពេលប្រជាជនកាប់ព្រៃឈើត្រូពិកសម្រាប់ប្រើប្រាស់ក្នុងកសិដ្ឋាននិងក្នុងទីក្រុងនៅប្រទេសអាហ្វ្រិក, ជំងឺឡែសស្មានញ៉ា គ្រុនលឿង និងជំងឺងងុយដេក ក៏បានរាតត្បាត។ វាគឺជាជំងឺឆ្លងរាលដាលដោយសារសត្វល្អិតដែលបង្កកំណើតនៅពេលទឹកលិច ដែលទឹកនេះគួរតែជ្រាបចូលក្នុងដី, ហើយសត្វដែលស៊ីសត្វល្អិតទាំងនេះ បានបាត់បង់ជម្រករបស់វា។
- នៅពេលដើមឈើជាច្រើននៅក្នុងប្រទេសអាមេរិកខាងត្បូងត្រូវបានកាប់បំផ្លាញ, ចំនួនកណ្ដុរជើងសបានកើនឡើងដោយសារអាហាររបស់វាមានកាន់តែច្រើន ហើយចំនួនសត្វដែលស៊ីកណ្ដុរទាំងនេះបានថយចុះ។ កណ្ដុរទាំងនេះផ្ទុកជំងឺមួយដែលហៅថា ជំងឺប្រព័ន្ធទឹកឡាំ, បន្ទាប់មកវាចម្លងទៅមនុស្ស។

### ឱសថរុក្ខជាតិពឹងផ្អែកលើជីវចម្រុះ

ឱសថស្ទើរតែទាំងអស់ត្រូវបានផលិតឡើងពីរុក្ខជាតិ។ នៅពេលដើមឈើត្រូវបានកាប់បំផ្លាញ ហើយទន្លេនិងដីល្បាយខ្សាច់បានស្ងួតអស់ នោះយើងនឹងបាត់បង់រុក្ខជាតិទាំងនេះជាច្រើន។ យើងក៏បាត់បង់ចំណេះដឹងបែបបុរាណអំពីវិធីប្រើប្រាស់រុក្ខជាតិទាំងនេះដើម្បីព្យាបាលជំងឺផងដែរ។

ការការពារជីវចម្រុះ និងសំណាញ់នៃជីវិត គឺការពារវប្បធម៌និងការព្យាបាលបែបបុរាណរបស់យើង។



**អ្នកដែលប្រើប្រាស់រុក្ខជាតិឱសថ ច្រើនតែដាំដុះនិងថែទាំរុក្ខជាតិទាំងនេះ ដូច្នេះពួកគេការពារទាំងជីវចម្រុះនិងប្រពៃណីរបស់ខ្លួន។**

### របបអាហារសុខភាព ពឹងផ្អែកលើជីវចម្រុះ

សុខភាពល្អអាស្រ័យលើការបរិភោគអាហារចម្រុះ ដូចជាផ្លែឈើ បន្លែ គ្រាប់ធញ្ញជាតិ, និងអាហារក្នុងព្រៃ ដូចជា ផ្លែឈើតូចៗ ត្រី និងសត្វព្រៃ។ នៅពេលយើងបាត់បង់ជីវចម្រុះ យើងនឹងបាត់បង់អាហារជាច្រើនដែលចាំបាច់ក្នុងការធ្វើឲ្យរបបអាហាររបស់យើងមានសុខភាពល្អ។ បន្ទាប់មកសហគមន៍ទាំងមូលមានការប្រឈមនឹងបញ្ហាសុខភាពផ្សេងៗដែលបណ្ដាលមកពីអាហារូបត្ថម្ភមិនល្អ។



**ការដាំដំណាំច្រើនមុខ ជួយកែលម្អទាំងជីវចម្រុះ ទាំងរបបអាហារសុខភាព។**

មាលាដែលជាបុគ្គលិកសុខាភិបាលនៃគម្រោង"សុខភាពសម្រាប់ប្រជាជន" យល់យ៉ាងច្បាស់អំពីសំណាញ់នៃជីវិត។ ដោយសារឃ្មុំត្រូវការផ្កាដើម្បីផលិតទឹកឃ្មុំ ហើយដើមផ្កាត្រូវការឃ្មុំជួយវាឲ្យមានផ្លែ, ដូច្នេះទើបការដាំដើមឈើ និងការចិញ្ចឹមឃ្មុំ អាចជួយសហគមន៍ឲ្យមានអាហារ, ហើយក្នុងពេលជាមួយគ្នាក៏ជួយស្រោចស្រង់ឡើងវិញនូវសំណាញ់នៃជីវិតផងដែរ។

## ជីវចម្រុះកែលម្អទិន្នផលដំណាំ

ដំណាំទាំងឡាយ រួមទាំងស្រូវ ពោត ស្រូវសាឡី សុទ្ធតែត្រូវបានដាំដុះពីរុក្ខជាតិក្នុងព្រៃរាប់ពាន់ឆ្នាំមកហើយ។ ដំណាំទាំងនេះនៅតែពឹងផ្អែកលើសត្វល្អិតមានប្រយោជន៍និងសត្វដទៃទៀតដើម្បីឲ្យលូតលាស់បានល្អ។

កសិកម្មទំនើប, ដោយមានម៉ាស៊ីនធំៗ និងសារធាតុគីមី, អាចផលិតបានទិន្នផលដំណាំយ៉ាងខ្ពស់។ ប៉ុន្តែសារធាតុគីមីទាំងនេះសម្លាប់រុក្ខជាតិនិងសត្វល្អិតមានប្រយោជន៍ និងបំផ្លាញដី។ ប្រសិនបើផលិតផលកើនឡើង ជាទូទៅវាកើនឡើងសម្រាប់ដំណាំតែមួយមុខ និងកើនឡើងក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ប៉ុន្មានឆ្នាំក្រោយមក អាហារនឹងមានតិចតួច និងមិនមានច្រើនមុខ( ចម្រុះ )ដែលចាំបាច់សម្រាប់សុខភាពល្អនោះទេ។



**កសិកម្មដែលមានស្ថិរភាព ពឹងផ្អែកលើជីវចម្រុះ និងការពារជីវចម្រុះ។**

កសិដ្ឋានអាចផ្តល់ទិន្នផលច្រើន និងរងការប៉ះពាល់ពីបញ្ហាសត្វល្អិតចង្រៃតិចតួច ប្រសិនបើប្រើប្រាស់មធ្យោបាយដែលមានស្ថិរភាព។ វិធីសាស្រ្តទាំងនេះលើកកម្ពស់ជីវិតសត្វ និងសត្វល្អិតមានប្រយោជន៍, បង្កើនជីជាតិដីដោយប្រើជីធម្មជាតិ, និងការពារដីដោយការដាំឈើនិងរុក្ខជាតិ( មើលជំពូក15 )។ ទិន្នផលដំណាំចម្រុះ កែលម្អអាហារូបត្ថម្ភនិងសុខភាព សម្រាប់មនុស្សទាំងអស់។

## ជីវចម្រុះការពារប្រភពទឹក

ទាំងការកាប់បំផ្លាញព្រៃឈើ ទាំងកសិកម្មទំនើប ធ្វើឲ្យបាត់បង់សំណើមដី ហើយខ្សែទឹកទាំងឡាយរីងស្ងួតទឹកអស់នៅរដូវក្តៅ។ ជីគីមីនិងថ្នាំសម្លាប់សត្វល្អិត ផ្តល់ទិន្នផលដល់កសិកម្មទំនើប ប៉ុន្តែវាបំពុលទឹកទន្លេ និងបឹងនានា។

## ជីវចម្រុះការពារសហគមន៍

ការចិញ្ចឹមជីវិតច្រើនបែបយ៉ាង តែងតែពឹងផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិ។ នៅពេលដែលធនធានទាំងនោះត្រូវបានប្រើប្រាស់អស់ ភាពក្រីក្រនឹងកើនឡើង។ នៅក្នុងតំបន់កសិកម្ម កសិកម្មទំនើបបង្កើនបំណុលដល់មនុស្សខ្លះ និងបង្កើនភាពគ្មានដីធ្លីដល់មនុស្សជាច្រើន។

## ការស្រោចស្រង់សំណាញ់នៃជីវិត

នៅក្នុងសំណាញ់នៃជីវិត នៅពេលវត្ថុមានជីវិតមួយបានស្លាប់ វាធ្វើឲ្យប៉ះពាល់ដល់វត្ថុមានជីវិតដទៃទៀតជាច្រើន រួមទាំងមនុស្សផងដែរ។ សាច់រឿងនៅក្នុងជំពូក1 នៅពេលប្រជាជននៃទីក្រុងមែនក្លាវ៉ាល់តូ បានបាត់បង់ព្រៃឈើរបស់ខ្លួន ពួកគេក៏បាត់បង់ប្រភពអាហារ និងប្រាក់ចំណូលផងដែរ។ នៅពេលព្យុះបក់បោកនៅទីនោះ ពួកគេក៏បានបាត់បង់ផ្ទះសម្បែងថែមទៀត។ នៅពេលពួកគេចាប់ផ្តើមដាំដើមឈើឡើងវិញ អ្នកភូមិក៏បានយល់ឃើញថា ពួកគេកំពុងធ្វើការងារលើសពីការការពារសំណើកដី ឬការផលិតទឹកឃ្មុំទៅទៀត។ ការងាររបស់ពួកគេក្នុងការស្រោចស្រង់ស្ថានភាពដីឲ្យមានជីជាតិឡើងវិញ បានធ្វើឲ្យមានរុក្ខជាតិ និងសត្វជាច្រើនដែលមានសារប្រយោជន៍ដល់សុខភាពរបស់សហគមន៍ទាំងមូល។




## ការធ្វើការជាមួយធម្មជាតិ

នៅក្នុងធម្មជាតិ គ្មានអ្វីមួយដែលជាកាកសំណល់ទេ ព្រោះអ្វីៗទាំងអស់សុទ្ធតែអាចប្រើប្រាស់បាន។ វិធីមួយដែលធម្មជាតិប្រើប្រាស់ធនធានឡើងវិញដោយមិនមានសំណល់ គឺការធ្វើការនៅក្នុងវដ្តនៃធម្មជាតិ។ ជាអកុសល វដ្តធម្មជាតិត្រូវបានរំខានដោយសកម្មភាពមនុស្សនិងឧស្សាហកម្ម ហើយចំណុចនេះបាននាំឲ្យមានបញ្ហាសុខភាពបរិស្ថានធ្ងន់ធ្ងរ។ ឧទាហរណ៍នៃផលវិបាកដែលកើតឡើងនៅពេលវដ្តនៃធម្មជាតិត្រូវបានរំខាន គឺ**ការឡើងកម្តៅផែនដី** (មើលទំព័រ33)។



**ពពកបង្កើតទឹកភ្លៀង រួចធ្លាក់ចុះទៅលើផែនដី...**
**ទឹកហួតក្លាយជាពពក....**

## តើយើងអាចធ្វើតាមវដ្តធម្មជាតិបានយ៉ាងដូចម្តេច

អ្នកលើកកម្ពស់សុខភាពបរិស្ថាននៅក្នុងប្រទេស ហ្វីលីពីន មានសុភាសិតមួយពោលថា ៖




តាមរយៈការយល់ដឹងពីសារសំខាន់នៃការវិលត្រឡប់ ទៅដីវិញនូវអ្វីដែលចេញពីដី, យើងអាចធ្វើតាមធម្មជាតិ និងការពារ ធនធានធម្មជាតិ និងសុខភាពរបស់យើងបាន។ វដ្តទាំងឡាយដែលយើង បង្កើតឡើងនៅក្នុងផ្ទះ សហគមន៍ និងរោងចក្រ គឺជាជំហានតូចមួយឆ្ពោះទៅ កាន់ការកែលម្អសុខភាពបរិស្ថាន។ ឧទាហរណ៍ ការធ្វើជីកំប៉ុស និងការប្រើប្រាស់ឡើងវិញឬកែច្នៃដបទឹក និងកំប៉ុងផ្សេងៗ គឺជាវិធីដែលយើងធ្វើតាមគំរូរបស់ធម្មជាតិ ដោយការបង្កើតជាវដ្តមួយ ជាជាងការចាក់ កាកសំណល់។

## តើឧស្សាហកម្មអាចធ្វើតាមវដ្តធម្មជាតិបានយ៉ាងដូចម្តេច

អ្នកលើកកម្ពស់សុខភាពបរិស្ថាននៅក្នុងប្រទេសហ្វីលីពីន ក៏មានសុភាសិតមួយទៀតដែរ ដែលពោលថា ៖




ឧស្សាហកម្មបង្កឲ្យមានការបំពុលដោយសារសារធាតុពុល យ៉ាងច្រើនបំផុត។ ប៉ុន្តែសូម្បីតែឧស្សាហកម្ម ក៏អាចរៀនតាមវដ្តធម្មជាតិដែរ គឺតាមរយៈការប្រើប្រាស់ឡើងវិញនូវថាមពលនិងសម្ភារៈផ្សេងៗ នៅក្នុងដំណើរការ មួយដែលហៅថា **ផលិតកម្មស្អាត**។ ជំហានដំបូងគឺរោងចក្រត្រូវយកទៅវិញនូវសំណល់ទាំងអស់ដែលខ្លួន បានបង្កើត។ ប្រសិនបើសំណល់ ដូចជាសារធាតុគីមីពុល មិនអាចកែច្នៃឡើងវិញបានទេ, ឧស្សាហកម្មត្រូវតែ បោះវាចោលឲ្យមានសុវត្ថិភាព, ហើយកាត់បន្ថយ, និងចុងក្រោយគឺលែងប្រើប្រាស់វាតែម្តង។ ប្រសិនបើ ឧស្សាហកម្មមានកន្លែងបោះចោលកាកសំណល់ក្នុងរយៈពេលយូរ កន្លែងនោះត្រូវតែផ្អែកលើការបង្ការ, ការ ប្រុងប្រយ័ត្ន, និងសិទ្ធិក្នុងការធ្វើឲ្យមនុស្សគ្រប់គ្នាមានសុខភាពល្អ, គឺមិនមែនសិទ្ធិក្នុងការរកប្រាក់ចំណេញពី ឧប្បត្តិហេតុ, ការចាក់កាកសំណល់, និងជំងឺទេ។



**តាមរយៈការកាត់បន្ថយធនធានដែល ប្រើប្រាស់ និងការកែច្នៃនិងប្រើប្រាស់ ឡើងវិញនូវអ្វីដែលប្រើរួច, ឧស្សាហកម្មអាច កាត់បន្ថយគ្រោះថ្នាក់ដែលពួកគេ បង្កលើសុខភាពបរិស្ថានរបស់យើង។**

# ការបង្ការគ្រោះថ្នាក់ពីការបំពុលបរិស្ថាន

ការបំពុលបរិស្ថានគឺជាគ្រោះថ្នាក់សម្រាប់មនុស្សនិងបរិស្ថាន ដែលបណ្តាលមកពីភាពលើសលុបនៃសារធាតុពុលដែលជាលទ្ធផលនៃសកម្មភាពរបស់មនុស្ស ជាពិសេសកាកសំណល់ពីឧស្សាហកម្ម, ការដឹកជញ្ជូន, និងកសិកម្ម។ ការបំពុលនេះធ្វើដំណើរនៅក្នុងបរិស្ថាន នៅក្នុងខ្យល់ ទឹក និងដីរបស់យើង។

ការបំពុលបរិស្ថានភាគច្រើនបង្កឡើងដោយវត្ថុដែលយើងប្រើប្រាស់ ហើយមនុស្សជាអ្នកប្រឈមនឹងការបំពុលនេះរាល់ថ្ងៃ។ ស្ថានភាពញឹកញាប់បំផុតដែលប្រឈមនឹងការបំពុលពីសារធាតុពុល មានដូចជា ៖

- **ផ្សែងពីការដុត** ជាពិសេសនៅពេលដុតប្លាស្ទិក។ យើងដកដង្ហើមចូលនូវផ្សែងពុលទាំងនេះ, ហើយផេះពុលធ្វើឲ្យកខ្វក់ដល់ទឹកនិងដីស្រែចម្ការរបស់យើង។
- **ផ្សែងពីរោងចក្រ**ដែលបំពុលខ្យល់ ទឹក និងដី។
- **សារធាតុគីមី**ដែលបានប្រើប្រាស់នៅក្នុងរោងចក្រ, ការជីករករ៉ែ, និងការខួងយកប្រេង, ដែលត្រូវបានចាក់ទៅក្នុងប្រភពទឹក ហើយក៏បំពុលខ្យល់និងដីផងដែរ។
- **ថ្នាំសម្លាប់សត្វល្អិត**ដែលត្រូវបានប្រើប្រាស់និងរៀបចំនៅក្បែរអាហារ ប្រភពទឹក និងនៅផ្ទះ។ នៅពេលបាញ់, ថ្នាំនេះរសាត់នៅក្នុងខ្យល់បានយ៉ាងឆ្ងាយ ដែលបង្កគ្រោះថ្នាក់ជាខ្លាំង។
- **សារធាតុគីមី**នៅក្នុងអាគុយនិងថ្មពិល ក្នុងថ្នាំលាប ក្នុងថ្នាំជ្រលក់ក្រណាត់ និងពីការធ្វើអគ្គិសនី, ដែលបង្កគ្រោះថ្នាក់ដល់មនុស្សដែលធ្វើការជាមួយរបស់ទាំងនេះ។
- **ផ្សែងម៉ាស៊ីន**ពីរថយន្តដែលបំពុលខ្យល់ ទឹក និងដី។

ការបំពុលដោយសារសារធាតុពុល បង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់មនុស្ស រុក្ខជាតិ និងសត្វ, មិនត្រឹមតែនៅកន្លែងដែលវាត្រូវបានបញ្ចេញប៉ុណ្ណោះទេ តែថែមទាំងនៅទីឆ្ងាយៗពីប្រភពរបស់វាទៀតផង។ ការការពារខ្លួនយើងពីគ្រោះថ្នាក់ដែលបង្កឡើងដោយការបំពុលបរិស្ថាន និងសារធាតុគីមីពុល គឺជាផ្នែកដ៏សំខាន់មួយនៃសុខភាព (មើលទំព័រ42, 368, 410, 440, និងជំពូក14, 16 និង20 ទៅ23)។

# គោលការណ៍ប្រុងប្រយ័ត្ន

ក្នុងការស្រាវជ្រាវបង្កើតផលិតផលថ្មីៗ និងបង្កើនប្រាក់ចំណូលរបស់ខ្លួន, សាជីវកម្មបានបង្កើតសារធាតុគីមីរាប់ពាន់មុខដែលមិនធ្លាប់មាននៅក្នុងធម្មជាតិ។ សារធាតុគីមីទាំងនេះភាគច្រើនមិនទាន់មានការពិសោធន៍អំពីសុវត្ថិភាពនៅឡើយទេ។ ប៉ុន្តែវានៅតែបានប្រើប្រាស់នៅក្នុងផលិតផលផ្សេងៗដែលលក់ឲ្យយើងរាល់ថ្ងៃ។ សូម្បីតែនៅពេលប្រជាជនគិតថាសារធាតុគីមីទាំងនេះខ្លះ មានគ្រោះថ្នាក់ក្តី, បើពួកគេមិនអាចបញ្ជាក់ថាវាមានគ្រោះថ្នាក់មែនទេ នោះគេមិនអាចយកវាចេញពីទីផ្សារទេ - ឬយកវាចេញពីក្នុងខ្លួនយើងបានឡើយ។

អ្នកដឹកនាំប្រទេសនិងអ្នកវិទ្យាសាស្ត្រមួយចំនួន ប្រើប្រាស់**គោលការណ៍ប្រុងប្រយ័ត្ន**ក្នុងការសម្រេចចិត្តលើអ្វីមួយ។ គោលការណ៍ប្រុងប្រយ័ត្ននិយាយថា ៖

**ប្រសិនបើមានមូលហេតុដែលជឿជាក់ថាអ្វីមួយអាចបង្កគ្រោះថ្នាក់ បើទោះជាយើងមិនដឹងពិតប្រាកដក៏ដោយ, ជាការប្រសើរគឺត្រូវចៀសវាងវា ជាជាងការប្រថុយធ្វើអ្វីដែលគ្រោះថ្នាក់។**

*ការការពារប្រសើរជាងការព្យាបាល។*

គោលការណ៍នេះផ្ទុយគ្នាស្រឡះពីអ្វីដែលប្រទេសជាច្រើនកំពុងអនុវត្ត។ សព្វថ្ងៃអ្នកត្រូវបង្ហាញថាអ្វីមួយពិតជាមានគ្រោះថ្នាក់មែន ទើបពួកគេអាចបញ្ឈប់វា។ យើងហៅវាថា គោលការណ៍សាកសព។

# ការឡើងកម្ដៅផែនដី

នៅទូទាំងពិភពលោក សំណាញ់នៃជីវិតកំពុងត្រូវបានកាត់ផ្ដាច់។ ការកាប់បំផ្លាញព្រៃឈើ, ការកើនឡើងនៃការបំពុលក្នុងទឹកនិងខ្យល់, និងការបាត់បង់សត្វព្រៃ, គឺជាឧទាហរណ៍ដែលមើលឃើញនឹងភ្នែក។ ផលវិបាកដែលមើលមិនឃើញ គឺការកើនឡើងនៃកម្ដៅ ដែលបង្កឡើងដោយការបំពុលបរិស្ថាន។

បញ្ហានេះ, ដែលហៅថា**ការឡើងកម្ដៅផែនដី**, កំពុងតែផ្លាស់ប្ដូរ**បរិយាកាស**(លក្ខណៈនៃអាកាសធាតុនៅតំបន់មួយក្នុងរយៈពេលយូរមកហើយ) នៅស្ទើរគ្រប់ទីកន្លែងក្នុងពិភពលោក។ សីតុណ្ហភាពដែលហាក់ដូចជាកើនឡើងបន្តិចបន្តួច គឺកំពុងឈានទៅដល់ការប្រែប្រួលដ៏ធំ។ នៅកន្លែងខ្លះប្រជាជនជនកំពុងតែរងគ្រោះដោយទឹកជំនន់កាន់តែច្រើន និងព្យុះកាន់តែធ្ងន់ធ្ងរ, ហើយកន្លែងខ្លះទៀតកំពុងតែមានទឹកភ្លៀងតិចតួចនិងភាពរាំងស្ងួតជាច្រើន។ ពីមួយឆ្នាំទៅមួយឆ្នាំ ការប្រែប្រួលនៃបរិយាកាសដែលបណ្ដាលមកពីការឡើងកម្ដៅផែនដី កំពុងតែបង្កមហន្តរាយជាច្រើននៅទូទាំងពិភពលោក ដោយបង្កើតជាបញ្ហាធ្ងន់ធ្ងរជាច្រើនដល់សុខភាពរបស់មនុស្ស។

- ទឹកជំនន់ ព្យុះធ្ងន់ធ្ងរ និងភាពរាំងស្ងួត បណ្ដាលឲ្យបាត់បង់ដំណាំ ភាពអត់ឃ្លាន បាត់បង់ផ្ទះសម្បែង ការហូរច្រោះយ៉ាងច្រើន របួស និងការស្លាប់។
- ជំងឺមានកាន់តែធ្ងន់ធ្ងរ ឬឆ្លងរាលដាលយ៉ាងឆាប់រហ័ស ព្រោះការប្រែប្រួលអាកាសធាតុធ្វើឲ្យមានសត្វល្អិតនិងសត្វដែលចម្លងជំងឺកាន់តែច្រើន ហើយធ្វើឲ្យពួកវាផ្លាស់ទៅរកកន្លែងថ្មីៗ។
- ការឡើងសីតុណ្ហភាព ជួនកាលនាំឲ្យមានជំងឺនិងការស្លាប់កាន់តែច្រើន។

## មូលហេតុឫសគល់នៃការឡើងកម្ដៅផែនដី

បរិស្ថានមានសមត្ថភាពធម្មជាតិរបស់វាក្នុងការស្រូបយកនូវការបំពុល។ ប៉ុន្តែប្រសិនបើការបំពុលត្រូវបានចោលទៅក្នុងបរិស្ថានច្រើនពេក នោះផែនដីមិនអាចស្រូបយកវាបានទេ។ ជាង១០០ឆ្នាំចុងក្រោយនេះ នៅពេលមនុស្សចាប់ផ្ដើមទាញយក**ឥន្ធនៈហ្វូស៊ីល**(ដូចជាប្រេង និងធ្យូង) និងដុតវាក្នុងបរិមាណយ៉ាងច្រើន ទើបបរិមាណនៃការបំពុលដែលត្រូវបានបញ្ចេញទៅក្នុងបរិស្ថាន បានកើនឡើងយ៉ាងឆាប់រហ័សជាងពេលកន្លងមក។ នេះគឺជាមូលហេតុឫសគល់មួយនៃការឡើងកម្ដៅផែនដី។ ម្យ៉ាងទៀត សារធាតុគីមីដែលបង្កើតឡើងសម្រាប់ប្រើប្រាស់នៅក្នុងផលិតកម្មផ្សេងៗ ធ្វើឲ្យពុលដល់ខ្យល់ ហើយផែនដីមិនអាចស្រូបយកវាបាន។ ចំណុចនេះក៏រួមចំណែកក្នុងការឡើងកម្ដៅផែនដីដែរ។

មូលហេតុឫសគល់មួយទៀតនៃការឡើងកម្ដៅផែនដី គឺការប្រើប្រាស់ធនធានធម្មជាតិដោយគ្មានយុត្តិធម៌, មិនស្មើភាពគ្នា, និងគ្មានស្ថិរភាព។ បណ្ដាប្រទេសអ្នកមាន ដូចជាសហរដ្ឋអាមេរិក បានចាប់ផ្ដើមការឡើងកម្ដៅផែនដី ដោយការប្រើប្រាស់ធនធានច្រើនពេក និងបង្កឲ្យមានការបំពុលលើសលុប ដើម្បីការស្វែងរកប្រាក់ចំណូលខ្ពស់ និងគុណភាពជីវិតយ៉ាងល្អ។ នៅពេលបណ្ដាប្រទេសអ្នកក្រចាប់ផ្ដើមដើរតាមផ្លូវដូចគ្នានៃការអភិវឌ្ឍន៍គ្មានស្ថិរភាពបែបនេះ ផែនដីកាន់តែមិនអាចទប់ទល់នឹងការបំពុលនេះថែមទៀត។ ដើម្បីបង្ការគ្រោះមហន្តរាយដែលបង្កដោយការឡើងកម្ដៅផែនដីដូចរៀបរាប់ខាងលើ និងមហន្តរាយកាន់តែធ្ងន់ធ្ងរថែមទៀតដែលកំពុងរង់ចាំ, ទាំងប្រទេសអភិវឌ្ឍន៍ និង "អភិវឌ្ឍន៍ពុំពេញលេញ" ត្រូវតែផ្លាស់ប្ដូរទៅរកការប្រើប្រាស់ធនធនប្រកបដោយស្ថិរភាពវិញ។ ជាការសំខាន់គឺត្រូវឈប់ពឹងផ្អែកលើឥន្ធនៈហ្វូស៊ីល ហើយចាប់ផ្ដើមប្រើថាមពលស្អាតវិញ(មើលជំពូក23)។

